គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (គ.ប.ស.យ)
COMMITTEE FOR FREE AND FAIR ELECTIONS IN CAMBODIA (COMFREL)
ទីស្នាក់ការកណ្តាលផ្ទះលេខ១៣៨ ផ្លូវ១២២ សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Central Office: #138, St. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA.
P.O. Box 1145, Tel: (855) 23 884 150 Fax: (855) 23 883 750
E-mail: comfrel@online.com.kh Website: http://www.comfrel.org

ខុមហ្វ្រែល COMFREL

**គណៈកម្មាធិការនាយក**
BOARD OF DIRECTORS

1. លោក **ធុន សារាយ**
Mr. THUN SARAY
ប្រធានគណៈកម្មាធិការនាយក
និងជាប្រធាន ADHOC

2. លោក **សុក សំអឿន**
Mr. SOK Sam Oeun
អនុប្រធាន គណៈកម្មាធិការ
នាយក និងជានាយក CDP

3. លោក **យឹម ប៉ូ**
Mr. YIM Po អគ្គហេរញ្ញិក និងជា
នាយក CCPCR

4. **អ្នកស្រី ស៊ុន ចាន់សែន**
Mrs. SUN Chansen សមាជិកា និង
ជាប្រធាន KYA

5. លោក **យង់ គិមអេង**
Mr. YONG Kim Eng សមាជិក និងជា
នាយក PDP-Center

6. លោក **មុំ សារិន**
Mr. MOM Sarin សមាជិក និងជា
នាយក HRCDO

7. **អ្នកស្រី ទីវ សារាយេត**
Ms. TIV Sarayet សមាជិកា និងជា
សហនាយិកា WMC

8. **កញ្ញា សយ សារា វឌ្ឍនី**
Miss. SAY Sara Vathany សមាជិកា
និងជា នាយិកា CWCC

9. លោក **គីម សុវណ្ណ**
Mr. KIM Sovann សមាជិក និងជា
នាយក VIGILANCE

10. នាយក LAC (NA)

11. នាយក KKKHRO (NA)

12. **អ្នកស្រី ពឹង យក់ហៀប**
Ms. PEUNG Yok Hiep សមាជិកា ជា
ឥស្សរជន Dignitary

13. លោក **ស៊ីន សែត**
Mr. SEN Set សមាជិក ជា
ឥស្សរជន Dignitary

**ខុមហ្វ្រែល អ្នកឃ្លាំមើល / អត្ថបទលេខ ៨៦**

ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១០

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

## របាយការណ៍វេទិកាស្តីពីការបោះឆ្នោត និង ប្រជាធិបតេយ្យ ក្នុងខេត្តព្រៃវែង (FOREDS)

អ្នកតំណាងរាស្ត្រ ក្រុមប្រឹក្សាខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មន្ត្រីរាជការនៃមន្ទីរជុំវិញខេត្ត គណៈកម្មការរៀបចំការបោះឆ្នោតខេត្ត ឃុំ/សង្កាត់ តំណាងគណបក្សនយោបាយ អង្គការសង្គមស៊ីវិល និងប្រជាពលរដ្ឋ នៃខេត្តព្រៃវែង ប្រមាណ ៨៨ នាក់ ក្នុងនោះ មានស្ត្រីចំនួន ១២នាក់ បានចូលរួមនៅក្នុងវេទិកាស្តីពី "**ការបោះឆ្នោត និង ប្រជាធិបតេយ្យ**" ដែលបានរៀបចំឡើងដោយ គណៈកម្មាធិការ **ខុមហ្វ្រែល** សហការណ៍ជាមួយ អង្គការសមាគម មិនមែនរដ្ឋាភិបាល ក្នុងខេត្តព្រៃវែង ដូចជា **សមាគមការពារសិទ្ធិមនុស្សអាដហុក** (ADHOC) **ក្រុមប្រឹក្សាយុវជនកម្ពុជា** (YCC ) **អង្គការប្រតិបត្តិការណ៍ដើម្បីកាត់បន្ថយភាពក្រីក្រ** ( COFAP ) **អង្គការអតីតយុទ្ធជនអន្តរជាតិ** (VI) **អង្គការ រក្សាការពារសិទ្ធិមនុស្សនៅកម្ពុជា** ( VIGILANCE) ក្រោមការគាំទ្រថវិកាពីអង្គការ UNDP នៅរោងភាពយន្ត **ពានមាស** ក្នុងទីរួម ខេត្តព្រៃវែង កាលពីថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ២០១០កន្លងទៅនេះ។

ក្នុងឱកាសនោះក៏មានវត្តមានឯកឧត្តម **យ៉ែម បុញ្ញាឫទ្ធិ** អ្នកតំណាងរាស្ត្រគណបក្សសិទ្ធិមនុស្ស មណ្ឌលព្រៃវែង ឯកឧត្តម **សៅ រ៉ានី** អ្នកតំណាងរាស្ត្រគណបក្សជាតិនិយម មណ្ឌលព្រៃវែង និង លោក **ថ្នាក់ សំអឿន** អនុប្រធានដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ លោក **សុក សំអឿន** អនុប្រធានគណកម្មាធិការនាយកខុមហ្វ្រែល និងជា នាយកប្រតិបត្តិ អង្គការក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា និងលោក **យង់ គិមអេង** សមាជិកគណកម្មាធិការនាយកខុមហ្វ្រែល និងជាប្រធានមជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាព។

គោលបំណង របស់វេទិកាគឺ ផ្តល់ឱកាសឱ្យអ្នកពាក់ព័ន្ធបានលើកឡើង និងពិភាក្សាគ្នាពីបញ្ហាដែលទាក់ទងទៅនឹងដំណើការបោះឆ្នោត និងប្រជាធិបតេយ្យនៅកម្ពុជា ហើយស្វែងរកនូវអនុសាសន៍ ឬយុទ្ធសាស្ត្រ និងរកការគាំទ្រលើអនុសាសន៏ទាំងនោះ។

ក្នុងវេទិកានេះ សិក្ខាកាមបានរកឃើញអនុសាសន៍ដើម្បីកែលំអរ បញ្ហាជាអត្ថិភាពប្រាំរួមមាន : ការរៀបចំគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ( គ.ជ.ប) ការចុះបញ្ជីឈ្មោះអ្នកបោះឆ្នោត ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយក្នុងពេលបោះឆ្នោត សេរីភាពបញ្ចេញមតិ និងសេរីភាពប្រមូលផ្តុំ។

មានការខ្វែងយោបល់អំពីអនុសាសន៍មួយទាក់ទងការចុះឈ្មោះបោះឆ្នោតពិសេសទំរង់ ១០១៨ រវាងសិក្ខាកាម និងរវាងវាគ្មិន។

នៅក្នុងឱកាសនោះ ឯកឧត្តម **យ៉ែម បុញ្ញាឫទ្ធិ** បានលើកឡើងថា " ខ្ញុំស្នើសុំម្តងហើយម្តងទៀតឱ្យលប់ចោលទំរង់ ១០១៨...។ ...ខ្ញុំស្នើសុំឱ្យអាជ្ញាធរមូលដ្ឋានសូមលោកមេត្តាអនុវត្តច្បាប់ បាតុកម្មអហឹង្សា អោយបានល្អប្រសើរ..." ។

ដោយឡែកឯកឧត្តម **សោ រ៉ានី** បានលើកឡើងដែរថា "ខ្ញុំឯកភាពក្នុងការលប់ទំរង់ ១០១៨... រកវិធីផ្សេងជំនួស ១០១៨" ។

ចំណែកលោក **ច្រាក់ សំអឿន** បានមានចំណាប់អារម្មណ៏ថា "... ពាក់ព័ន្ធបញ្ហាទំរង់១០១៨ គ.ជ.ប ហ្នឹង ក្រសួងមហាផ្ទៃបានបង្កើតក្រុមការងារអន្តរក្រសួងមួយដើម្បីដោះស្រាយបញ្ហានេះ... មានគល់បញ្ជី និងនីតិវិធីចេញឱ្យច្បាស់លាស់...ខិតខំឱ្យមានអត្តសញ្ញាណប័ណ្ណឱ្យបានគ្រប់ៗគ្នា..." ។

ក្រៅពីអនុសាសន៏ទាក់ទងការចុះឈ្មោះបោះឆ្នោត ទំរង់ ១០១៨ វាគ្មិនជាអ្នកតំណាងរាស្ត្រគាំទ្រអនុសាសន៏ទាំងអស់ ។ ចំណែកតំណាងក្រសួងមហាផ្ទៃថា នឹងខិតខំពិនិត្យអនុសាសន៏ទាំងនេះ។ លោក **គល់ បញ្ញា** អ្នកសំរបសំរួលវេទិកា និងជានាយកប្រតិបត្តិខុមហ្វ្រែល សន្យាថានឹងរៀបចំអនុសាសន៏ទាំងនេះឱ្យមានលក្ខណៈរៀបរយ ហើយនឹងបញ្ជូនបន្តទៅស្ថាប័នពាក់ព័ន្ធទាំងអស់ ។

ទោះបីយ៉ាងណាក៏ដោយ ក្រោយពីបានជជែកពិភាក្សាគ្នាយ៉ាងយកចិត្តទុកដាក់សិក្ខាកាមនៃវេទិកាបានបោះឆ្នោតគាំទ្រ (៦0% ទៅ ៨0%) អនុសាសន៏របស់ខ្លួនដែលបង្ហាញឱ្យឃើញដូចមានភ្ជាប់នៅក្នុងតារាងខាងក្រោម ។

| **អនុសាសន៍របស់ម្ចាស់ឆ្នោតនៅខេត្តព្រៃវែង ចូលរួមវេទិកាស្តីពី ការបោះឆ្នោត និង ប្រជាធិបតេយ្យ** | | | |
|---|---|---|---|
| ល.រ | អនុសាសន៏ | ស្ថាប័នទទួលខុសត្រូវ | ភាគរយសំឡេង |
| ១ | **គណកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប)** | | |
| | គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតថ្នាក់ជាតិ(គ,ជ,ប)ត្រូវមានសមាសភាព ចំរុះពីគណបក្សនយោបាយដែលមានអាសនៈក្នុង រដ្ឋសភា និងតំណាងសង្គមស៊ីវិល។ យ៉ាងហោចណាស់ សមាជិកត្រូវមានការលាលែងពីគណបក្សរបស់ខ្លួនមុន នឹងក្រោយមួយឆ្នាំ ។ | រដ្ឋសភា និង រដ្ឋាភិបាល | គាំទ្រ : ៧៣% មិនគាំទ្រ: ១៥% អនុបវាទ:១២% |
| | គណៈកម្មការរៀបចំការបោះឆ្នោតរាជធានី ខេត្ត (PEC) គណៈកម្មការរៀបចំបោះឆ្នោត ឃុំ សង្កាត់ (CEC) គណៈកម្មការការិយាល័យបោះឆ្នោត (PSC) ក៏ត្រូវមានសមាសភាពចំរុះពីគណបក្សនយោបាយដែលមាន អាសនៈនៅក្នុងសភា និងតំណាងសង្គមស៊ីវិល។ ប្រសើរចំពោះការលាលែងពីសមាជិកបក្សតាមបទបញ្ជា និងនីតិវិធីរបស់ គ,ជ,ប។ ត្រូវបន្ថែមរយៈពេលបណ្តុះបណ្តាលដល់មន្ត្រី (CEC) និង (PSC) មួយអាទិត្យអំពីក្រមសីលធម៌ និងនីតិវិធីក្នុងការបោះឆ្នោត។ | គ.ជ.ប | |
| ២ | **បញ្ជីឈ្មោះបោះឆ្នោត និងការចុះឈ្មោះបោះឆ្នោត** | | |
| | រក្សាទុកទម្រង់១០១៨ នៅដដែល ប៉ុន្តែត្រូវមានការគ្រប់គ្រងការចេញទំរង់នេះ ឱ្យមានតម្លាភាព និងសុក្រឹតត្រូវបិទការធ្វើទម្រង់នេះមុនថ្ងៃបោះឆ្នោតមួយថ្ងៃត្រឹមម៉ោង ៥ ល្ងាច។ ធ្វើការកែសម្រួលបញ្ជីឈ្មោះអ្នកបោះឆ្នោត ដោយបង្កើនសមត្ថភាពអ្នកបញ្ចូលទិន្នន័យបញ្ជីឈ្មោះអ្នកបោះឆ្នោត លើមន្ត្រី គ,ជ,ប។ ប័ណ្ណព័តិមានអ្នកបោះឆ្នោតគួររក្សាជាប្រចាំ (រៀងរាល់អាណត្តិបោះឆ្នោត)។ | គ.ជ.ប | គាំទ្រ : ៨0% មិនគាំទ្រ: ១២% អនុបវាទ: ៣% |
| | ការធ្វើទម្រង់១០១៨ គឺជាបន្ទុករបស់មេឃុំ សង្កាត់ ប៉ុន្តែត្រូវលើកទឹកចិត្តឱ្យមានអ្នកសង្កេតការណ៏ | អាជ្ញាធរមូលដ្ឋាន | |

| | | |
|---|---|---|
| ចេញពីក្រុមប្រឹក្សាគណបក្សនយោបាយផ្សេងៗ។ ការធ្វើអត្តសញ្ញាណប័ណ្ណចល័តនៅតាមភូមិត្រូវកំណត់ពេលឱ្យបានពីរខែ។ អត្តសញ្ញាណប័ណ្ណត្រូវបានប្រើសំរាប់រយៈពេលអស់មួយជីវិត។ | និងអ្នកអនុវត្តច្បាប់ | |
| ៣ **ប្រព័ន្ធផ្សព្វផ្សាយ** | | |
| ជួយសំរួលដល់ការបង្កើតប៉ុស្តិ៍វិទ្យុ ទូរទស្សន៍ ដែលមិនមែនមនុស្សរបស់គណបក្សកាន់អំណាច ឬរដ្ឋាភិបាល គួរតែបង្កើតក្រុមប្រឹក្សានៃការចាក់ផ្សាយដែលមានសមាជិកជាសង្គមស៊ីវិល និងមកពីគ្រប់គណបក្ស។ | រដ្ឋសភា និងរដ្ឋាភិបាល | គាំទ្រ : ៨០%<br>មិនគាំទ្រ:១២%<br>អនុបវាទៈ ៣% |
| ត្រូវធានាថាវិទ្យុ ទូរទស្សន៍ផ្តល់លទ្ធភាពស្មើៗគ្នាដល់គណបក្សនយោបាយនានា ដើម្បីថ្លែងទៅកាន់អ្នកបោះឆ្នោតទាំងក្នុងអំឡុងពេលឃោសនាបោះឆ្នោត និងក្រោយពេលបោះឆ្នោត។ សុំឱ្យមានការពិន័យ ឬដាក់ទោសដល់បេក្ខជន ឬគណបក្សណាដែលមិនបានគោរព ក្រមសីលធម៌ និងច្បាប់ស្តីពីការបោះឆ្នោត។ | គ. ជ. ប | |
| បង្កើតជាប៉ុស្តិ៍ ឬកម្មវិធីផ្សាយតាមទូរទស្សន៍ និងវិទ្យុឯករាជ្យមួយ ផ្សព្វផ្សាយដោយមិនលំអៀងលើគណបក្សនយោបាយដែលផលិតព័ត៌មានវិជ្ជមាន និងអវិជ្ជមានទៅសំរាប់សាធារណៈជន។ | អង្គការសង្គមស៊ីវិល | |
| ត្រូវគោរពក្រមសីលធម៌ ក្នុងការឃោសនាបោះឆ្នោត និងច្បាប់ស្តីពីការបោះឆ្នោត។ | គណបក្សនយោបាយ | |
| ៤ **សេរីភាពនៃការបញ្ចេញមតិ** | | |
| ច្បាប់ដែលប៉ះពាល់ដល់ការបញ្ចេញមតិអ្នកតំណាងរាស្ត្រ ត្រូវបានធ្វើវិសោធនកម្ម ដែលបើកសិទ្ធិទូលំទូលាយ ក្នុងន័យការពារអភ័យឯកសិទ្ធិអ្នកតំណាងរាស្ត្រ។ មតិរបស់ប្រជាពលរដ្ឋ និងគណបក្សនយោបាយ មិនគួរចាត់ទុកជាបទល្មើសព្រហ្មទណ្ឌ។ គួរតែធ្វើការផ្សព្វផ្សាយអំពីច្បាប់ ដែលពាក់ព័ន្ធបញ្ចេញមតិដល់សាធារណៈជនឱ្យបានយល់ជ្រួតជ្រៀបចៀសវាងការចោទប្រកាន់ផ្សេងៗ ។ ត្រូវមានសេចក្តីណែនាំដល់កងកំលាំងប្រដាប់អាវុធ ដើម្បីអនុវត្តតួនាទីក្នុងការការពារ អ្នកសម្តែងមតិ។ | រដ្ឋសភា និងរដ្ឋាភិបាល | គាំទ្រ : ៦២%<br>មិនគាំទ្រៈ ៣២%<br>អនុបវាទៈ ៦% |
| គ.ជ.ប គួរតែមានគណបក្សនយោបាយ និងសង្គមស៊ីវិល ដើម្បីធានាឯករាជ្យ។ | គ.ជ.ប | |
| ៥ **សេរីភាពនៃប្រមូលផ្តុំ** | | |
| ធ្វើវិសោធន៏កម្មច្បាប់ស្តីពីការធ្វើ បាតុកម្មអហឹង្សាលើចំណុចនៃការចូលរួមធ្វើបាតុកម្មសន្តិភាព ដែលកុំឱ្យមានការកំណត់ចំនួនមនុស្ស។ សុំឱ្យ បង្កើតច្បាប់មួយពីការដាក់ទោសដល់អាជ្ញាធរ ដែលបង្កបញ្ហារារាំងសេរីភាពនៃការប្រមូលផ្តុំ។ | រដ្ឋសភា និងរដ្ឋាភិបាល | គាំទ្រ : ៧៣%<br>មិនគាំទ្រៈ ១៩%<br>អនុបវាទៈ ៨% |
| ស្នើឱ្យមានភាពអព្យាក្រិត្យក្នុងការដោះស្រាយបញ្ហាកុំឱ្យមានការរើសអើងគណបក្សនយោបាយដែលធ្វើសកម្មភាពឃោសនាបោះឆ្នោត បើមានបញ្ហាត្រូវដោះស្រាយជាបន្ទាន់។ | គ.ជ.ប | |
| ជូនដំណឹងទៅអាជ្ញាធរត្រឹមមួយអាទិត្យជាមុន ក្នុងការប្រមូលផ្តុំប្រជាពលរដ្ឋដើម្បីសំដែងមតិ។ | អាជ្ញាធរមូលដ្ឋាន និងអ្នកអនុវត្តច្បាប់ | |

សំរាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង លោក **ច័ន្ទ ដារិទ្ធ** (អ្នកសម្របសម្រួលព័ត៌មាន ខុមហ្វ្រែល) ទូរស័ព្ទលេខ : **០១២ ៨៤៦ ២១១**